**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៦២៥ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី៣០ខែកក្កដា ឆ្នាំ ២០០៧

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការកំណត់តម្លៃសំបុត្រចូលទស្សនាសារមន្ទីរជាតិ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និង
## រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦.០២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រមលេខ ០១ /នស/ ៩៣ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥

ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ១៩៩៩ ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យ ប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះ ថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០២ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦

- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- អនុវត្តតាមអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- អនុវត្តតាមបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ ០៤ បប ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- អនុវត្តតាមប្រកាសលេខ ០០៤ សហវ.មប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- អនុវត្តតាមសារាចរណែនាំលេខ ០០២ សហវ.ម ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីវដ្តទេយ្យចំណូល
- តាមការចាំបាច់របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## សម្រេច

**ប្រការ ១ :** អនុញ្ញាតឱ្យលក់សំបុត្រចូលទស្សនាសារមន្ទីរជាតិនៃព្រះរាជាណាចក្រកម្ពុជា សំរាប់ជនជាតិខ្មែរ និងជនជាតិបរទេស លើកលែងតែ សិស្ស និស្សិត កងប្រដាប់អាវុធ ព្រះសង្ឃ ជនពិការ ជាសញ្ជាតិខ្មែរ និងគណៈប្រតិភូដែលមានលិខិតអនុញ្ញាតពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

**ប្រការ ២ :** តម្លៃសំបុត្រចូលទស្សនាសារមន្ទីរជាតិនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានកំណត់ដូចតទៅ :

- ៥០០ ( ប្រាំរយ ) រៀល ក្នុងម្នាក់ សំរាប់ជនជាតិខ្មែរ
- ០៣ ( បី ) ដុល្លារអាមេរិកក្នុងម្នាក់ សំរាប់ជនជាតិបរទេស

**ប្រការ ៣ :** ជនជាតិខ្មែរ និងជនបរទេស ដែលមានបំណងចូលទស្សនាសារមន្ទីរជាតិនៃព្រះរាជាណាចក្រកម្ពុជា ដោយមិនបានទិញសំបុត្រ នោះមិនត្រូវបានអនុញ្ញាតឱ្យចូលទស្សនាឡើយ ។

**ប្រការ ៤ :** ការបោះពុម្ពសំបុត្រចូលទស្សនាសារមន្ទីរជាតិ ត្រូវអនុវត្តតាមច្បាប់ និង លិខិតបទដ្ឋានជាធរមាន ។

**ប្រការ ៥ :** ការគ្រប់គ្រងចំណូលពីសារមន្ទីរជាតិត្រូវបានកំណត់ដូចខាងក្រោម : ៥៧០

ក- ចំណូលពីការចូលទស្សនាសារមន្ទីរជាតិ ត្រូវអនុវត្តតាមនីតិវិធីនៃកិច្ចប្រតិបត្តិការថវិកាទូទៅរបស់រដ្ឋ និងត្រូវបានកត់ត្រាក្នុងជំពូក ៧៣ គណនី ៧៣០ អនុគណនី ៧៣០៤' តាមមាតិកាថវិការដ្ឋនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៧។

ខ- ចំណូលពីការចូលទស្សនាសារមន្ទីជាតិត្រូវបង់ចូលរតនាគារជាតិ ឬធនាគារជាតិ ១០០ % តាមរយៈរដ្ឋទេយ្យករចំណូលក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

គ-ការប្រមូលចំណូលពីការលក់សំបុត្រចូលទស្សនាសារមន្ទីរជាតិរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវមានសហការចូលរួមផ្ទៀងផ្ទាត់ និងត្រួតពិនិត្យដោយផ្ទាល់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ឃ-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវបូកសរុប និងធ្វើរបាយការណ៍ចំណូលប្រចាំខែ រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានទៀងទាត់។

**ប្រការ ៦ :** បទបញ្ញត្តិ ឬប្រកាសទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៧ :** គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀង១ខ្លួន ។

**ប្រការ ៨ :** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**រដ្ឋមន្ត្រី**
**ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

**ហ៊ឹម ឆែម**

**ចម្លងជូនៈ**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ទីស្តីការគណៈរដ្ឋមន្ត្រី

-អាជ្ញាធរសវនកម្មជាតិ

-គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ

-គ្រប់សាលាខេត្ត-ក្រុង

"ដើម្បីជូនជ្រាប"

-ដូចប្រការ ៧ "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ